សន្និសីទស្រាវជ្រាវថ្នាក់ជាតិលើកទី ១ ឆ្នាំ ២០២៦

វិទ្យាស្ថានជាតិអប់រំ

# ការប្រើប្រាស់ការសិក្សាតាមដានអតីតគរុនិស្សិតបរិញ្ញាបត្រ ជាន់ខ្ពស់អប់រំវិជ្ជាជីវៈគ្រូបង្រៀនកម្រិតឧត្តម ដើម្បីកែលម្អកម្មវិធី

## The Use of Tracer Study in Improving Master Degree Program of Education in Upper-Secondary School Teaching,

បង្ហាញដោយ

លោក ឈិត លៀងអៀង

# មាតិកា នៃការស្រាវជ្រាវ

១. សេចក្តីផ្តើម
២. គោលបំណង
៣. វិធីសាស្ត្រនៃការស្រាវជ្រាវ
៤. លទ្ធផលនៃការស្រាវជ្រាវ
៥. សេចក្តីសន្និដ្ឋាន
៦. អនុសាសន៍

References

## ១. សេចក្តីផ្តើម

- វិទ្យាស្ថានជាតិអប់រំបានបង្កើតឡើងតាំងពីឆ្នាំ១៩១៤ ‘សាលាបឋមសិក្សាហ្វ្រង់ស្វ័រប៉ូដឺវ៉ាំង”
- ២០០៤ ប្រែឈ្មោះជា **‘វិទ្យាស្ថានជាតិអប់រំ”**

**ចក្ខុវិស័យ៖**

**ជាមជ្ឈមណ្ឌលឧត្តមភាពក្នុងការអប់រំ អភិវឌ្ឍវិជ្ជាជីវៈ និង ការស្រាវជ្រាវ**

**បេសកម្ម**

- **លើកកម្ពស់ការបង្រៀន និងរៀនសម្រាប់សតវត្សរ៍ទី ២១**
- **ការអភិវឌ្ឍវិជ្ជាជីវជាប្រចាំរបស់គ្រូបង្រៀន**
- **អ្នកដឹកនាំវិស័យអប់រំ និង អ្នកស្រាវជ្រាវនៅកម្ពុជា**

# ១. សេចក្តីផ្តើម (cont.)

រចនាសម្ព័ន្ធគ្រប់គ្រងរបស់ វិទ្យាស្ថានជាតិអប់រំ




**មហាវិទ្យាល័យគរុកោសល្យ**

- **ដេប៉ា.អប់រំវិទ្យាសាស្ត្រ គណិត បច្ចេកវិទ្យាព័ត៌មាន និង អប់រំបច្ចេកវិទ្យា**
- **ដេប៉ា.អប់រំវិទ្យាសាស្ត្រសង្គម សិល្បៈ មនុស្សសាស្ត្រ និង ភាសាបរទេស**
- **ដេប៉ា.ចិត្ត គរុកោសល្យ និង សិក្សាអប់រំ**

## ១. សេចក្តីផ្តើម (ត)

❖ ចំនួនគរុនិស្សិត ជំនាន់ទី ២ ទាំង ១៩ ឯកទេស

| ល.រ | ឯកទេសបរិញ្ញាបត្រ+២ | ក្រុម | ចំនួនសរុប | ស្រី |
|---|---|---|---|---|
| ១ | អក្សរសាស្ត្រខ្មែរ | ៤ | ១០៨ | ១០២ |
| ២ | គណិតវិទ្យា | ៤ | ១០០ | ២០ |
| ៣ | ភាសាអង់គ្លេស | ៣ | ៦៦ | ២៣ |
| ៤ | រូបវិទ្យា | ៣ | ៧០ | ៣៩ |
| ៥ | គីមីវិទ្យា | ៣ | ៦៨ | ៤១ |
| ៦ | ភូមិវិទ្យា | ២ | ៤២ | ២៥ |
| ៧ | ព័ត៌មានវិទ្យា | ២ | ៥៩ | ១៣ |
| ៨ | ជីវវិទ្យា | ២ | ៥៨ | ៤១ |
| ៩ | ផែនដីវិទ្យា | ២ | ៤៧ | ២៩ |
| ១០ | ប្រវត្តិវិទ្យា | ២ | ៥៦ | ២២ |
| ១១ | សីលធម៌ ពលរដ្ឋវិជ្ជា | ១ | ៣០ | ១៣ |

# ១. សេចក្ដីផ្ដើម ( ត )

❖ ចំនួនគរុនិស្សិត ជំនាន់ទី ២ ទាំង ១៩ ឯកទេស

| | | | | |
|---|---|---|---|---|
| ១២ | កែច្នៃអាហារ | ១ | ២ | ១ |
| ១៣ | អេឡិចត្រូនិក | ១ | ៣ | ១ |
| ១៤ | មេកានិក | ១ | ៤ | ០ |
| ១៥ | បសុវប្បកម្ម | ១ | ៤ | ២ |
| ១៦ | ក្សេត្រសាស្ត្រ | ១ | ៤ | ២ |
| ១៧ | អគ្គិសនី | ១ | ៥ | ០ |
| ១៨ | វិស្វកម្មកុំព្យូទ័រ | ១ | ១៨ | ៤ |
| ១៩ | សេដ្ឋកិច្ច | ១ | ២១ | ១១ |
| សរុប | | ៣៦ | ៧៦៥ | ៣៨៩ |

# មូលហេតុនៃការបង្កើតកម្មវិធី «បរិញ្ញាបត្រ + ២»

✓ ដំណើរការកែទម្រង់គរុកោសល្យ និងការពង្រឹងគុណភាពអប់រំនៅកម្ពុជា

**កម្មវិធី បរិញ្ញាបត្រ + ១ (អតីតកាល)**

-សិក្សារយៈពេលតែ ១ ឆ្នាំ ដែលផ្តោតខ្លាំងទៅលើទ្រឹស្តីទូទៅក្នុងថ្នាក់។

-ពេលវេលាសម្រាប់អនុវត្តជាក់ស្តែងនៅមានកម្រិតខ្លី ដែលពិបាកក្នុងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរល្បឿននៃសាលារៀនជំនាន់ថ្មី និងស្តង់ដារតំបន់អាស៊ាន។

**កម្មវិធី បរិញ្ញាបត្រ + ២ (បច្ចុប្បន្ន)**

-កែសម្រួលឡើងទៅជា ២ ឆ្នាំ ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់ក្នុងការក្រេបជញ្ជក់វិជ្ជាជីវៈ។

- បន្ថែមម៉ោងបង្ហាត់បង្រៀនជាក់ស្តែង កម្មសិក្សាគរុកោសល្យ បន្ថែមបច្ចេកវិទ្យា EdTech STEM និងបណ្តុះវប្បធម៌ក្នុងការស្រាវជ្រាវ។

**គុណសម្បត្តិនៃការបន្ថែមរយៈពេលសិក្សាដែលមាន ៤៨ ក្រេឌីត គឺ** ដើម្បីធានាថាគរុនិស្សិតមានពេលវេលាគ្រប់គ្រាន់ក្នុងការពង្រឹងសមត្ថភាព៖

- ឆ្នាំទី ១៖ ពង្រឹងទ្រឹស្តីគរុកោសល្យ វិធីសាស្ត្របង្រៀនឯកទេស និងរៀបចំគម្រោងស្រាវជ្រាវអប់រំ។
- ឆ្នាំទី ២៖ ចុះកម្មសិក្សាហាត់បង្រៀនពេញលេញ (Practicum) នៅតាមវិទ្យាល័យដៃគូ ដើម្បីទទួលបានការណែនាំ និងបទពិសោធន៍ផ្ទាល់ក្នុងថ្នាក់ និង បង្ហាញលទ្ធផលការស្រាវជ្រាវ។

# ៣. គោលបំណង និង សំណួរស្រាវជ្រាវ

**គោលបំណង**

**សំណួរស្រាវជ្រាវ**

ពិនិត្យមើលលើការអនុវត្តកម្មវិធីសិក្សាបរិញ្ញាបត្រជាន់ខ្ពស់អប់រំវិជ្ជាជីវៈគ្រូបង្រៀន BA +2 តាមរយៈអតីតគរុនិស្សិត ដើម្បីកែលម្អកម្មវិធីសិក្សា

→

តើគ្រូថ្មីពី NIE ( កម្មវិធីបរិញ្ញាបត្រ + ២ )មានចំណេះដឹងឯកទេស ចំណេះដឹងលើវិធីសាស្រ្តបង្រៀន និង ឥរិយាបថយ៉ាងដូចម្តេច ?

# ៣. វិធីសាស្ត្រនៃការស្រាវជ្រាវ

## គម្រោងសិក្សាស្រាវជ្រាវ



# ៣. វិធីសាស្ត្រនៃការស្រាវជ្រាវ (ត)

## ការជ្រើសរើសសំណាកនៃការស្រាវជ្រាវ:

Multiphase sampling

- Stratified sampling គ្រប់ខេត្តក្នុងប្រទេសកម្ពុជា (២៥ ខេត្ត, 25 Provinces)
- Cluster Sampling វិទ្យាល័យនៅទីប្រជុំជន និង ដាច់ស្រយាល (107 high schools)
- Purposive sampling សម្រាប់ការសង្កេតថ្នាក់ និង សម្ភាសនាយក និង ប្រធានក្រុមបច្ចេកទេស .
- **Convenience sampling** អតីតគរុនិស្សិត (គ្រូថ្មី)ចំនួន ៣៦៣ បានធ្វើការស្ទង់មតិ

# ៤. លទ្ធផលនៃការស្រាវជ្រាវ

## លទ្ធផលពីការស្ទង់មតិអតីតគរុនិស្សិត (គ្រូថ្មី)

*Table 1* **Demographic information of the participants for questionnaires** *(N=363)*




*Table 2* **Demographic Information of the Participants for** *(N=363)*




*Table 3* **Demographic Information of the Participants for Classroom Observation** *(N=4)*

# 4. លទ្ធផលការស្រាវជ្រាវ

*Table 3* លទ្ធផលពី ការស្ទង់មតិអតីតគរុនិស្សិត *(N=៣៦៣)*




Most of the respondents generally in **good** and **very good** answer in each items. There are only a few respondents were rated **excellent** and probably they hesitates to place themselves in excellence.

*Table 3* លទ្ធផលពី ការស្ទង់មតិអតីតគរុនិស្សិត *(N=៣៦៣)*




តើអ្នកមានការយល់ដឹង ពីការរៀបចំកិច្ចតែងការបង្រៀនកម្រិតណា ?
ល្អណាស់ ( ខ្ញុំរៀបចំកិច្ចតែងការបង្រៀនរបស់ខ្ញុំ ហើយឆ្លុះបញ្ចាំងវាបន្ទាប់ពីចប់ថ្នាក់រៀន )
38
ល្អ ( ខ្ញុំតែងតែរៀបចំកិច្ចតែងការបង្រៀនរបស់ខ្ញុំ )
258
មធ្យម ( ពេលខ្លះខ្ញុំមិនបានរៀបចំកិច្ចតែងការបង្រៀនរបស់ខ្ញុំទេ )
67
0
50
100
150
200
250
300


ការវាយតម្លៃខ្លួនឯង អំពីវិន័យ និងការប្តេជ្ញាចិត្តរបស់អ្នកជាគ្រូបង្រៀន
ល្អណាស់ ( ខ្ញុំចាប់ផ្តើមបង្រៀនថ្នាក់របស់ខ្ញុំដោយមិនខកពេល
118
ល្អ ( ខ្ញុំមកសាលាទាន់ពេលវេលា )
232
មធ្យម ( ពេលខ្លះខ្ញុំទៅបង្រៀនយឺត )
13
0
50
100
150
200
250

## *Table 3* លទ្ធផលពី ការស្ទង់មតិអតីតគរុនិស្សិត (*N=៣៦៣*)

### ការវាយតម្លៃខ្លួនឯងអំពីកម្រិតចំណេះដឹងមុខវិជ្ជារបស់អ្នក សម្រាប់ការបង្រៀន របស់អ្នក។




### ការវាយតម្លៃខ្លួនឯង អំពីកម្រិតគរុកោសល្យ សម្រាប់ការបង្រៀនរបស់អ្នក។



# ចំណេះដឹងឯកទេស

តាមរយៈការសង្កេតថ្នាក់ សម្ភាសនាយក ប្រធានក្រុមបច្ចេកទេស និងសិស្សរបស់អតីតគរុនិស្សិត

គ្រូបង្រៀនមានចំណេះដឹងឯកទេសល្អប្រសើរ និងមានសមត្ថភាពអនុវត្តការបង្រៀនប្រកបដោយប្រសិទ្ធភាព ដោយមានការយល់ដឹងស៊ីជម្រៅលើមុខវិជ្ជាឯកទេស និងបកស្រាយខ្លឹមសារមេរៀនបានត្រឹមត្រូវ។

ក្នុងការបង្រៀនមានឧទាហរណ៍ជាក់ស្តែង និងផ្សារភ្ជាប់មេរៀនទៅនឹងជីវភាពប្រចាំថ្ងៃ ព្រមទាំងអនុវត្តការបង្រៀនស្របតាមគោលការណ៍គរុកោសល្យ និងជំហានកិច្ចតែងការបង្រៀន។

**ចំណេះដឹងឯកទេស**

ខ្លឹមសារមេរៀនត្រូវបានរៀបចំឡើងមានលំដាប់លំដោយ អាចឆ្លើយសំណួររបស់សិស្សបានក្បោះក្បាយ និងមានភាពបត់បែនវិធីសាស្ត្របង្រៀនទៅតាមសមត្ថភាពសិស្ស



គ្រូក៏បានប្រើប្រាស់សម្ភារៈឧបទេស និងបច្ចេកវិទ្យាអប់រំ ដូចជា LCD វីដេអូ ផែនទី សន្លឹកកិច្ចការ និងសម្ភារៈពិសោធន៍ ព្រមទាំងបានដឹកនាំសិស្សអនុវត្តជាក់ស្តែងក្នុងបន្ទប់ពិសោធន៍ ការដាំដុះ ការកែច្នៃអាហារ និងគម្រោងផ្សេងៗផងដែរ។

# ចំណេះដឹងលើវិធីសាស្ត្របង្រៀន

តាមរយៈការសង្កេតថ្នាក់ សម្ភាសនាយក ប្រធានក្រុមបច្ចេកទេស និងសិស្សរបស់អតីតគរុនិស្សិត

## ចំណេះដឹងវិធីសាស្ត្របង្រៀន

គ្រូមានសមត្ថភាពវិជ្ជាជីវៈល្អក្នុងការបង្រៀន ដោយបានអនុវត្តវិធីសាស្ត្របង្រៀនសមស្រប និងទាន់សម័យ។ ក្នុងការអនុវត្តជាក់ស្តែង គ្រូបានប្រើប្រាស់វិធីសាស្ត្របង្រៀនចម្រុះ ដូចជា PBL, IBL, 5Es, Cooperative Learning, Jigsaw និងការធ្វើបទបង្ហាញ ព្រមទាំងបានបង្កើតបរិយាកាសសិក្សាបែបសិស្សមជ្ឈមណ្ឌល ដែលអនុញ្ញាតឱ្យសិស្សធ្វើការងារជាក្រុម សួរដេញដោល និងអនុវត្តជាក់ស្តែង។

គ្រូក៏មានសមត្ថភាពគ្រប់គ្រងថ្នាក់រៀនបានល្អ រក្សាសណ្តាប់ធ្នាប់ និងជម្រុញការចូលរួមរបស់សិស្ស តាមរយៈការប្រើសំណួរបំផុសគំនិត និងការទុកពេលឱ្យសិស្សពិចារណាមុននឹងឆ្លើយ។

លំហូរមេរៀនត្រូវបានរៀបចំឡើងជាប្រព័ន្ធ ចាប់តាំងពីការបំផុសចំណាប់អារម្មណ៍ រហូតដល់ការសន្និដ្ឋានមេរៀន ដោយមានការប្រើប្រាស់បច្ចេកវិទ្យា និងសម្ភារៈឧបទេសយ៉ាងមានប្រសិទ្ធភាពក្នុងដំណើរការបង្រៀន។

វិធីសាស្ត្របង្រៀនទាំងនេះត្រូវបានកែសម្រួលទៅតាមសមត្ថភាពជាក់ស្តែងរបស់សិស្ស ដោយស្តែងឱ្យឃើញពីភាពច្នៃប្រឌិត និងភាពបត់បែនខ្ពស់ក្នុងការបង្រៀន ដើម្បីធានាបាននូវការអប់រំមួយដែលយកសិស្សជាមជ្ឈមណ្ឌលយ៉ាងពិតប្រាកដ

# ឥរិយាបថ

តាមរយៈការសង្កេតថ្នាក់ សម្ភាសនាយក ប្រធានក្រុមបច្ចេកទេស និងសិស្សរបស់អតីតគរុនិស្សិត

**ឥរិយបថ**

វិន័យ និងសីលធម៌ការងារ៖ ការគោរពពេលវេលា គោរពបទបញ្ជាផ្ទៃក្នុង និងមានភាពម៉ត់ចត់ខ្ពស់ក្នុងការគ្រប់គ្រងឯកសាររដ្ឋបាល និងបច្ចេកទេស ស្លៀកពាក់ និងការប្រាស្រ័យទាក់ទងមានសុជីវធម៌ និងសមរម្យជាគ្រូបង្រៀន។

មានភាពអត់ធ្មត់លើការបំពេញការងារ

ឥរិយាបទ និងភាពយុត្តិធម៌ចំពោះសិស្ស៖ មានភាពរួសរាយរាក់ទាក់ មានយុត្តិធម៌ក្នុងការវាយតម្លៃលទ្ធផលសិក្សា និងយកចិត្តទុកដាក់ខ្ពស់លើការកសាងផ្លូវចិត្ត សីលធម៌ និងបំណិនជីវិតដល់សិស្ស។

ការចូលរួមសកម្មក្នុងសង្គម និងសហគមន៍៖ បានចូលរួមយ៉ាងសកម្មក្នុងសកម្មភាពសាលា និងបង្កើតទំនាក់ទំនងល្អជាមួយអាណាព្យាបាល សហគមន៍ និងអ្នកពាក់ព័ន្ធ។

## បញ្ហាប្រឈម

❖ សម្ភារៈរូបវន្ត និង សម្ភារៈឧបទេស

-សាលារៀនជាច្រើននៅតែជួបប្រទះនូវកង្វះខាតឧបករណ៍បច្ចេកវិទ្យាចាំបាច់ ដូចជា កុំព្យូទ័រ, LCD Projector និងសេវាអ៊ីនធឺណិត ដែលធ្វើឱ្យការអនុវត្តការបង្រៀនបែបឌីជីថល និងការស្រាវជ្រាវរបស់គ្រូនិងសិស្សមានកម្រិត។

- ការខ្វះបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ និងសម្ភារៈពិសោធន៍ចាំបាច់ បានរាំងដល់ការអនុវត្តសកម្មភាពផ្ទាល់របស់សិស្ស ជាពិសេសមុខវិជ្ជា STEM ដែលប៉ះពាល់ដល់ការយល់ដឹងអំពីសារធាតុគីមី ប្រតិកម្មគីមី និងការអនុវត្តសុវត្ថិភាពក្នុងពិសោធន៍។

-ការរៀបចំឯកសារគោល និងសម្ភារៈឧបទេស ជាពិសេសសម្រាប់ថ្នាក់អប់រំបច្ចេកទេស នៅមិនទាន់មានភាពពេញលេញ និងមានប្រសិទ្ធភាពនៅឡើយទេ។

- ថ្នាក់រៀនមួយចំនួនមានសភាពក្តៅខ្លាំង (ដំបូលស័ង្កសី) ខ្វះផាសុកភាព និងមិនសមស្របសម្រាប់ការរៀបចំសកម្មភាពក្រុម ឬការរៀនបែបសកម្មនោះឡើយ។

❖ ធនធានមនុស្ស និងកត្តាគ្រូបង្រៀន

-សាលារៀនភាគច្រើនខ្វះគ្រូបង្រៀន ដែលបង្ខំឱ្យគ្រូមួយចំនួន ជាពិសេសអតីតគរុនិស្សិត ត្រូវបង្រៀនខុសឯកទេសរបស់ខ្លួន ដែលកត្តានេះបានជះឥទ្ធិពលអវិជ្ជមានដល់គុណភាពនៃការបង្រៀន ព្រមទាំងធ្វើឱ្យគ្រូខ្វះថ្នាក់រៀនបង្រៀនលើមុខវិជ្ជាឯកទេស និងខ្វះឱកាសទទួលបានការជានាលើមុខវិជ្ជាច្បាស់លាស់។

- គណៈគ្រប់គ្រងសាលា និង ប្រធានក្រុមបចេកទេសមួយចំនួន នៅមិនទាន់បានទទួលការបណ្តុះបណ្តាលបន្ថែមលើវិធីសាស្ត្របង្រៀនថ្មីៗ ដូចជា Inquiry-Based Learning (IBL), Project-Based Learning (PBL) និង 5Es Model នៅឡើយទេ ធ្វើឱ្យពួកគាត់ពិបាកវាយតម្លៃការបង្រៀនរបស់អតីតគរុនិស្សិត ហើយការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀនក៏នៅមានកម្រិតទាបដែរ។

- គ្រូថ្មីមួយចំនួនទៀតនៅខ្វះបទពិសោធន៍ និងភាពចាស់ទុំក្នុងការគ្រប់គ្រងថ្នាក់រៀន និងការអនុវត្តការងារ ដែលនាំឱ្យមានបញ្ហាទាក់ទងនឹងការលើកទឹកចិត្ត និងឥរិយាបថមិនសមស្របមួយចំនួនពីសំណាក់សិស្សចំពោះគ្រូ ដែលកត្តាទាំងអស់នេះបានជះឥទ្ធិពលអាក្រក់ និងប៉ះពាល់ដល់បរិយាកាសសិក្សារួមនៅក្នុងថ្នាក់រៀន។

## បញ្ហាប្រឈម (ត)

### ❖ ការគ្រប់គ្រងថ្នាក់រៀន និងកត្តាសិស្ស

- **ចំនួនសិស្សច្រើនពេក៖** ជាមធ្យម ៥០ ទៅ ៧០ នាក់ក្នុងមួយថ្នាក់ ធ្វើឱ្យគ្រូពិបាកគ្រប់គ្រងវិន័យ ពិបាកតាមដានការងារជាបុគ្គល និងពិបាកអនុវត្តវិធីសាស្ត្របង្រៀនសកម្ម។
- **កម្រិតសមត្ថភាពសិស្ស៖** សិស្សមានចំណេះដឹងមូលដ្ឋានខ្សោយ (សិស្សខ្លះមិនទាន់ចេះអាន) ហើយមានភាពខុសគ្នាខ្លាំងរវាងសិស្សពូកែ និងសិស្សយឺត ដែលបង្កការលំបាកដល់ការរៀបចំមេរៀនឱ្យសមស្របនឹងគ្រប់គ្នា។ សិស្សមួយចំនួនពុំសូវចាប់អារម្មណ៍នឹងការសិក្សាលើមុខវិជ្ជា ដែលមិនទាក់ទងនឹងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

### ❖ វិធីសាស្ត្របង្រៀន និងការអនុវត្តកិច្ចតែងការ

- **ការអនុវត្តវិធីសាស្ត្រថ្មី៖** គ្រូថ្មីមិនទាន់អនុវត្តវិធីសាស្ត្របង្រៀនសកម្មបានពេញលេញដោយសារកង្វះពេលវេលា សម្ភារៈ និងចំនួនសិស្សច្រើន។
- **គុណភាពនៃសំណួរ៖** ការរៀបចំសំណួរវាយតម្លៃនៅមិនទាន់ដល់កម្រិតត្រិះរិះពិចារណាស៊ីជម្រៅនៅឡើយ។
- **ការបង្រៀន និងការសង្ខេបខ្លឹមសារមេរៀន៖** ការបង្រៀនរបស់គ្រូនៅមិនទាន់មានការសង្ខេបខ្លឹមសារមេរៀនឱ្យបានខ្លី ខ្លឹម និងងាយយល់នៅឡើយ
- **គ្រូមួយចំនួនមិនធ្វើកិច្ចតែងការ និង ការរៀបចំនិងអនុវត្តកិច្ចតែងការបង្រៀននៅតែមានភាពខ្វះខាតមួយចំនួន៖** ដូចជា ការកំណត់វត្ថុបំណងមេរៀនមិនទាន់ច្បាស់លាស់ ការគ្រប់គ្រងពេលវេលាក្នុងថ្នាក់មិនទាន់សមស្រប

### ❖ ការគាំទ្រ និងការសហការ

- **ការគាំទ្រពីគណៈគ្រប់គ្រងសាលា៖** នាយកសាលាមួយចំនួននៅមិនទាន់ផ្តល់ការគាំទ្រ និងព័ត៌មានត្រឡប់បានគ្រប់ជ្រុងជ្រោយ ព្រមទាំងខ្វះការចុះអធិការកិច្ចជាប្រចាំ ដើម្បីផ្តល់មតិកែលម្អដល់គ្រូក្នុងការបង្រៀន។
- **ការចូលរួមពីអាណាព្យាបាលសិស្ស៖** ការប្រាស្រ័យទាក់ទងរវាងសាលា និងអាណាព្យាបាលនៅមានកម្រិត
- **កត្តាជីវភាពគ្រូបង្រៀនថ្មី៖** គ្រូថ្មីមួយចំនួនជួបការលំបាកផ្នែកជីវភាព ដោយសារសាលាស្ថិតនៅឆ្ងាយពីទីលំនៅ កង្វះកន្លែងស្នាក់នៅសមរម្យ និងការចំណាយប្រចាំថ្ងៃខ្ពស់ ដែលអាចជះឥទ្ធិពលដល់សុខុមាលភាព និងប្រសិទ្ធភាពការងារ។

ការវាយតម្លៃជារួម ដើម្បីការអនុវត្តកម្មវិធី BA +2នេះបានជោគជ័យ លុះត្រាតែមានការចូលរួមអនុវត្ត
1. ចូលរួមគាំទ្រ និង ថែរក្សា ពីអ្នកប្រើប្រាស់
2. មានការចង្អុលបង្ហាញលើបច្ចេកទេសបានត្រឹមត្រូវពីវជអ
3. អតីតគរុនិស្សិតខ្លួនឯង

- **វិទ្យាស្ថានជាតិអបរំ៖** គាំទ្រលើផ្នែកបច្ចេកទេស នៃក្នុងកម្មវិធីសិក្សាដល់នាយកសាលា ដែលយកគរុនិស្សិត ទៅប្រើ
- **ការចូលរួមពីអាណាព្យាបាលសិស្ស៖** ការប្រាស្រ័យទាក់ទងរវាងសាលា និងអាណាព្យាបាលនៅមានកម្រិត
- **កត្តាជីវភាពគ្រូបង្រៀនថ្មី៖** គ្រូថ្មីមួយចំនួនជួបការលំបាកផ្នែកជីវភាព

- **នាយក និង ប្រធានក្រុមបច្ចេកទេស ៖**
- អភិវឌ្ឍចំណេះដឹង (វិធីសាស្ត្របង្រៀនថ្មីៗ)
- ការចុះអធិការកិច្ចជាប្រចាំ ដើម្បីផ្តល់មតិកែលម្អដល់គ្រូក្នុងការបង្រៀន។
- **ការចូលរួមពីអាណាព្យាបាលសិស្ស៖** ការប្រាស្រ័យទាក់ទងរវាងជាមួយគ្រូថ្មី ធ្វើឱ្យពួកគាត់ចង់បំពេញការនៅទីនោះ
- **ក្រសួងអប់រំថ្មី៖** គ្រូថ្មីមួយចំនួនជួបការលំបាកផ្នែកជីវភាពពេលចេញបំរើការ

- **គ្រូបង្រៀនថ្មីខ្លួនឯង៖**
- **គ្រូថ្មីត្រូវតែធ្វើកិច្ចតែការបង្រៀនជាប្រចាំ**
- គ្រូថ្មីត្រូវតែច្បាស់លើចំណេះដឹងឯកទេស និង វិធីសាស្ត្រ
- គ្រូថ្មីត្រូវតែបន្តការស្រាវជ្រាវ

# ៦.សេចក្តីសន្និដ្ឋាន

តាមរយៈការចុះពិនិត្យតាមដាន និងវាយតម្លៃការរៀន និងការបង្រៀនរបស់អតីតគរុនិស្សិតបរិញ្ញាបត្រជាន់ខ្ពស់វិជ្ជាជីវៈគ្រូបង្រៀនកម្រិតឧត្តម (បរិញ្ញាបត្រ+២) ជំនាន់ទី១ និងជំនាន់ទី២ នៃវិទ្យាស្ថានជាតិអប់រំ (NIE) បានបង្ហាញថា កម្មវិធីបណ្តុះបណ្តាលមានប្រសិទ្ធភាពខ្ពស់ក្នុងការអភិវឌ្ឍធនធានមនុស្សដែលមានចំណេះដឹង សមត្ថភាពវិជ្ជាជីវៈ និងឥរិយាបថសមស្របសម្រាប់បំពេញតួនាទីជាគ្រូបង្រៀនក្នុងបរិបទអប់រំសតវត្សរ៍ទី២១ រួមមាន៖

- សមត្ថភាពវិជ្ជាជីវៈ៖ អតីតគរុនិស្សិតមានមូលដ្ឋានចំណេះដឹងឯកទេសរឹងមាំ អនុវត្តកិច្ចតែងការបង្រៀនតាមជំហានបានត្រឹមត្រូវ និងមានភាពក្បោះក្បាយក្នុងការបកស្រាយខ្លឹមសារមេរៀន។
- វិធីសាស្ត្របង្រៀនទំនើប៖ មានភាពច្នៃប្រឌិតក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀនសកម្ម (Active Learning) ព្រមទាំងការប្រើប្រាស់បច្ចេកវិទ្យា (ICT) និងការផ្សារភ្ជាប់មេរៀនទៅនឹងជីវភាពជាក់ស្តែងរបស់សិស្ស។
- ឥរិយាបទវិជ្ជាជីវៈ៖ ទទួលបានការកោតសរសើរខ្ពស់ពីភាគីពាក់ព័ន្ធ (នាយកសាលា សហការី សិស្ស) ចំពោះវិន័យការគោរពពេលវេលា សុជីវធម៌ និងការចូលរួមសកម្មក្នុងសកម្មភាពសាលា និងសហគមន៍។

## ៧. អនុសាសសន៍

- ✓ កម្មវិធីគួរតែមានគិតគូរឱ្យបានម៉ត់ចត់លើវិធីសាស្រ្តបង្រៀនដែលអាចទៅរួចគ្រប់កាលៈទេសៈ
- ✓ វិទ្យាស្ថាន គួរមានសៀវភៅណែនាំពីរបៀបប្រើប្រាស់គ្រូថ្មីរបស់NIE ( Employee Handbook, Staff Manual, ឬ Company Playbook )

គ្រូថ្មីមានឥទ្ធិពលលើលទ្ធផលនៃការប្រឡងថ្នាក់ជាតិប៉ុណ្ណា

# Thank for Your Attention!!!

# Triangulation

Use different data sources to reinforce finding for sample or multiple RQ


WELCOME TO
U.S. EMBASSY
PHNOM PENH
DELEGATION
Phnom Penh, Cambodia
UNITED STATES EMBASSY
PHNOM PENH